ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខ...៨៦៥ សជណ.ល

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០១៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

## ជម្រាបជូន

**-ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**-ឯកឧត្ដម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**-ឯកឧត្ដម អភិបាល នៃគណៈអភិបាលខេត្តក្រចេះ**

**កម្មវត្ថុ៖** របាយការណ៍ស្ដីពីលទ្ធផល នៃកិច្ចប្រជុំរបស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ចចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥។

**យោង** ៖ -របាយការណ៍ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៥។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូន **ឯកឧត្ដម** ជ្រាបថា៖ ចំពោះរបាយការណ៍របស់គណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០១៥ ទាក់ទងនឹងការវាយតម្លៃក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចចំនួន **១១** ក្រុមហ៊ុន ស្ថិតក្នុងខេត្តក្រចេះ រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

**-ខេត្តក្រចេះ**

**១-ក្រុមហ៊ុន** PHU RIENG KRATIE APHIVAT CAOUTCHOUC Co., Ltd ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន PHU RIENG KRATIE APHIVAT CAOUTCHOUC Co., Ltd ដែលមានទីតាំងស្ថិតនៅ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃចំនួន **៧៤៧ (ប្រាំពីររយសែសិបប្រាំពីរ)** ហិកតា បន្ទាប់ពីបានកាត់ចេញផ្ទៃដីដែលដាំដុះមិនបាន ហើយកម្រិតការចុះបញ្ជីដីរដ្ឋត្រឹម **៧៤៧ (ប្រាំពីររយសែសិបប្រាំពីរ)** ហិកតា រួចចុះកិច្ចសន្យាឡើងវិញជាមួយក្រសួង

កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន PHU RIENG KRATIE APHIVAT CAOUTCHOUC Co., Ltd ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**២-ក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ដែលមានទីតាំងស្ថិតនៅ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំដុះរួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**៣-ក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី២) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី ២) ដែលមានទីតាំងស្ថិតនៅ ឃុំអូរគ្រៀង ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំដុះរួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន DONG NAI KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី២) ឡើងវិញឲ្យបានច្បាស់លាស់។

៣-គួរប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**៤-ក្រុមហ៊ុន DONG PHU KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន DONG PHU KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ដែលមានទីតាំងស្ថិតនៅ ឃុំអូរគ្រៀង ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំដុះរួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន DONG PHU KRATIE APHIVATH CAOUTCHOUC Co., Ltd (គម្រោងទី១) ឡើងវិញឲ្យបានច្បាស់លាស់។

៣-គួរប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**៥-ក្រុមហ៊ុន ដុង ភូ ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** (DONG PHU KRATIE APHIVATHCAOUTCHOUC CO.,LTD) **(គម្រោងទី ៣)៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ដុង ភូ ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** (DONG PHU KRATIE APHIVATH CAOUT-CHOUC CO.,LTD) **(គម្រោងទី ៣)** ដែលមានទីតាំងស្ថិតនៅ ឃុំវល្លសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដាំដុះរួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ដុង ភូ ក្រចេះ អភិវឌ្ឍន៍ កៅស៊ូ** (DONG PHU KRATIE APHIVATH CAOUT-CHOUC CO.,LTD) **(គម្រោងទី ៣)** ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ គ្រប់គ្រង។

**៦-ក្រុមហ៊ុន ភី ឌី អេ (ខេមបូឌា)៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ភី ឌី អេ (ខេមបូឌា)** មានទីតាំងស្ថិតនៅឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី **(បញ្ជាក់និយាមកា)** គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ភី ឌី អេ (ខេមបូឌា)** ឡើងវិញឲ្យបានច្បាស់លាស់។

៣-ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៧-ក្រុមហ៊ុន កាម៉ាដេនូ វេនឈ័រ (ខេមបូឌា) លីមីតធីត** KAMADHENU VENTURES (CAMBODIA) LIMITED **៖**

១-អនុញ្ញាតឲ្យក្រុមហ៊ុន **កាម៉ាដេនូ វេនឈ័រ (ខេមបូឌា) លីមីតធីត** KAMADHENU VENTURES (CAMBODIA) LIMITED ដែលមានទីតាំងស្ថិតនៅ ឃុំកោះខ្ញែរ ឃុំក្បាលដំរី និងឃុំអូរគ្រៀង ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីលើផ្ទៃដីដែលបានដាំដុះរួច ដោយទុករយៈពេល **០១ (មួយ) ឆ្នាំ** ដើម្បីតាមដាន

វឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ ហើយចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **កាម៉ាដេនូ វេនឈ័រ (ខេមបូឌា) លីមីតធីត KAMADHENU VENTURES (CAMBODIA) LIMITED** ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឲ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តក្រចេះ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

**៨-ក្រុមហ៊ុន ស៊ី អេច ភី ប៊ី ឌីវេឡុបមេន** (C H P B DEVELOPMENT Co.,Ltd) ៖

១- អនុញ្ញាតឲ្យក្រុមហ៊ុន **ស៊ី អេច ភី ប៊ី ឌីវេឡុបមេន (C H P B DEVELOPMENT Co.,Ltd)** ស្ថិតនៅឃុំជ្រោយបន្ទាយ ស្រុកព្រែកប្រសព្វ និង ឃុំវឌ្ឍនៈ ឃុំកំពង់ចាម ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមានលើផ្ទៃដីដែលបានដោះស្រាយផលប៉ះពាល់រួច ហើយចុះកិច្ចសន្យាឡើងវិញ និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ស៊ី អេច ភី ប៊ី ឌីវេឡុបមេន (C H P B DEVELOPMENT Co.,Ltd)** ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឲ្យបានហ្មត់ចត់។

៣-ប្រគល់ផ្ទៃដីកាត់ចេញទាំងអស់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះគ្រប់គ្រង។

៤- ប្រគល់ភារកិច្ចជូនគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្ត រៀបចំបែបបទបច្ចេកទេសគ្រប់គ្រងផ្ទៃដីដែលមានផលប៉ះពាល់ស្របតាមលិខិតបទដ្ឋានជាធរមាន។

**៩-ក្រុមហ៊ុន ស៊ី & វី គ្រុប** (C&V GROUP Co.,Ltd) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ស៊ី & វី គ្រុប (C&V GROUP Co.,Ltd)** ដែលមានទីតាំងស្ថិតនៅឃុំស្រែជិះ និងឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធីជាធរមាន និងកែសម្រួលរយៈពេលវិនិយោគពី **៧០ (ចិតសិប) ឆ្នាំ** មកជា **៥០ (ហាសិប) ឆ្នាំ**។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (**បញ្ជាក់និយាមកា**) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ស៊ី & វី គ្រុប (C&V GROUP Co.,Ltd)** ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឲ្យបានហ្មត់ចត់។

**១០-ក្រុមហ៊ុន ឆាយណា ដាយណាមិក អ៊ិនវេសមេន** (CHINA DYNAMIC INVESTMENT Co.,Ltd ) ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **ឆាយណា ដាយណាមិក អ៊ិនវេសមេន** (CHINA DYNAMIC INVESTMENT Co.,Ltd) ស្ថិតនៅដែលមានទីតាំងស្ថិតនៅ ឃុំរលួសមានជ័យ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធី និងកែសម្រួលរយៈពេលវិនិយោគពី ៧០ (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ។

២-ប្រគល់ភារកិច្ចជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធ កំណត់ព្រំប្រទល់ដី (បញ្ជាក់និយាមកា) គម្រោងវិនិយោគសម្បទានដីសេដ្ឋកិច្ចក្រុមហ៊ុន **ឆាយណា ដាយណាមិក អ៊ិនវេសមេន** (CHINA DYNAMIC INVESTMENT Co.,Ltd) ឡើងវិញឲ្យបានច្បាស់លាស់ និងជំរុញការអនុវត្តផែនការមេឲ្យបានហ្មត់ចត់។

**១១-ក្រុមហ៊ុន អិន ខេ អេគ្រី (ខេមបូឌា) លីមីតធីត** N.K.AGRI ( CAMBODIA ) LIMITED ៖

១-អនុញ្ញាតឲ្យក្រុមហ៊ុន **អិន ខេ អេគ្រី (ខេមបូឌា) លីមីតធីត** N.K.AGRI (CAMBODIA) LIMITED ដែលមានទីតាំងស្ថិតនៅឃុំកោះខ្ញែរ ឃុំក្បាលដំរី ឃុំសំបូរ និងឃុំសណ្តាន់ ស្រុកសំបូរ ខេត្តក្រចេះ បន្តនីតិវិធី ដោយទុករយៈពេល ០១ (មួយ) ឆ្នាំ ដើម្បីតាមដានវឌ្ឍនភាព និងកែសម្រួលរយៈពេលវិនិយោគពី **៧០** (ចិតសិប) ឆ្នាំ មកជា ៥០ (ហាសិប) ឆ្នាំ និងចុះកិច្ចសន្យាឡើងវិញ។

២-ប្រគល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តក្រចេះ ត្រួតពិនិត្យ តាមដានអំពីវឌ្ឍនភាពរបស់ក្រុមហ៊ុននេះឲ្យបានហ្មត់ចត់បំផុត។ ក្នុងករណីដែលក្រុមហ៊ុនមិនបានអនុវត្តត្រឹមត្រូវក្នុងរយៈពេលកំណត់ខាងលើក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរាយការណ៍ជូនគណៈកម្មការអន្តរក្រសួងដើម្បីមានវិធានការ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម ជ្រាប និងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**គីមរ៉េត សំរេច**

**ចម្លងជូន៖**
-ក្រសួងមហាផ្ទៃ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងធនធានទឹក និងឧតុនិយម
-ក្រសួងបរិស្ថាន
-ក្រសួងរ៉ែ និងថាមពល
-អង្គភាពប្រឆាំងអំពើពុករលួយ
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម-លោកជំទាវឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី
-សមាជិកគណៈកម្មការអន្តរក្រសួងដើម្បីត្រួតពិនិត្យ វាស់វែង និងវាយតម្លៃសម្បទានដីសេដ្ឋកិច្ច
-ឯកសារ-កាលប្បវត្តិ